


# កសិរុក្ខកម្ម


**រៀបចំដោយ៖** វិទ្យាស្ថានសិក្សាស្រាវជ្រាវ និងបណ្តុះបណ្តាល

**គាំទ្រថវិកាដោយ៖** សហភាពអឺរ៉ុបប្រចាំព្រះរាជាណាចក្រកម្ពុជា

**តាមរយៈ៖** គម្រោងផ្តល់សេវាកម្មបរិស្ថានប្រកបដោយចីរភាពនៃអង្គការសត្វព្រៃ និងរុក្ខជាតិអន្តរជាតិ

**ចងក្រង**


Dr. Joel Jurgens

យស់ កាតង់

យ៉ុន សាមេត

ហ៊ាង សុផល

ស៊ីវ សុខឌី

សុង គឹមសាន


**រចនា**


លឹម គីមសុង


**កែសម្រួលជាភាសាខ្មែរ**


យស់ កាតង់

ស៊ីវ សុខឌី



"សៀវភៅបណ្តុះបណ្តាលនេះត្រូវបានផលិតឡើងក្រោមជំនួយសហភាពអឺរ៉ុប។ ខ្លឹមសារដែលបានបង្ហាញក្នុងសៀវភៅនេះ គឺជាការទទួលខុសត្រូវរបស់ វិទ្យាស្ថានសិក្សាស្រាវជ្រាវ និងបណ្តុះបណ្តាល និងអង្គការសត្វព្រៃ និងរុក្ខជាតិអន្តរជាតិ ដោយមិនឆ្លុះបញ្ចាំងពីទស្សនៈរបស់សហភាពអឺរ៉ុបឡើយ។"



២០១៤ រក្សាសិទ្ធិគ្រប់យ៉ាង

# បុព្វកថា

គម្រោងផ្តល់សេវាកម្មបរិស្ថានប្រកបដោយចីរភាព (SPES) គឺជាគម្រោងសាកល្បងមួយដែលទទួលបានការគាំទ្រមូលនិធិពីសហភាពអឺរ៉ុប (EU) តាមរយៈអង្គការសត្វព្រៃ និងរុក្ខជាតិអន្តរជាតិ (FFI)។ វិទ្យាស្ថានសិក្សាស្រាវជ្រាវ និងបណ្តុះបណ្តាល (The Learning Institute) គឺជាដៃគូសហការក្នុងការអនុវត្តគម្រោងនេះលើផ្នែកបង្កើនការយល់ដឹង និងផ្តល់នូវសេវាកម្មបរិស្ថានប្រកបដោយចីរភាព នៅតំបន់ជួរភ្នំក្រវាញទៅដល់អាជ្ញាធរ និងសហគមន៍មូលដ្ឋាន។ ចាប់តាំងពីចុងឆ្នាំ២០១១ ក្រុមការងារគម្រោងបានផ្តល់វគ្គបណ្តុះបណ្តាលដល់អ្នកពាក់ព័ន្ធគម្រោងទៅលើប្រធានបទដូចជា ១. ការគ្រប់គ្រងធនធានធម្មជាតិ ២. ការប្រាស្រ័យទាក់ទង និងការកសាងបណ្តាញ ៣. ភាពជាអ្នកដឹកនាំ និងការរៀបចំសហគមន៍ និង ៤. ការរៀបចំផែនការដោយមានការចូលរួម។

លើសពីនេះទៀត វិទ្យាស្ថានសិក្សាស្រាវជ្រាវ និងបណ្តុះបណ្តាល និង អង្គការសត្វព្រៃ និងរុក្ខជាតិអន្តរជាតិ បានព្រមព្រៀងគ្នារៀបចំសៀវភៅបណ្តុះបណ្តាលស្តីពីមូលដ្ឋានគ្រឹះនៃកសិរុក្ខកម្ម សម្រាប់ជាជំនួយដល់ប្រជាសហគមន៍ ដើម្បីយកទៅអនុវត្តជាក់ស្តែងនៅមូលដ្ឋានរៀងៗខ្លួន ក៏ដូចជាបន្តចែករំលែកឲ្យទូលំទូលាយផងដែរ។

វិទ្យាស្ថានសិក្សាស្រាវជ្រាវ និងបណ្តុះបណ្តាល សង្ឃឹមថា សៀវភៅបណ្តុះបណ្តាលនេះនឹងរួមចំណែកយ៉ាងធំធេងក្នុងការបង្កើនចំណេះដឹងដល់ប្រជាសហគមន៍ក្នុងគោលដៅលើកស្ទួយកម្រិតជីវភាពពួកគាត់ ក៏ដូចជារួមចំណែកក្នុងការការពារបរិស្ថាននៅតំបន់ដែលពួកគាត់រស់នៅ។

សៀវភៅបណ្តុះបណ្តាលនេះអាចនឹងមានចន្លោះខ្វះខាតជាក់ជាពុំខាន ហើយយើងខ្ញុំក៏សង្ឃឹមផងដែរថា អស់លោក លោកស្រី ដែលជាអ្នកប្រើប្រាស់ទាំងអស់នឹងជួយផ្តល់មតិយោបល់ល្អៗ ដើម្បីជួយកែលម្អឲ្យសៀវភៅនេះកាន់តែមានភាពសុក្រឹត និងភាពប្រសើរឡើង សម្រាប់ការបោះពុម្ព និងប្រើប្រាស់លើកក្រោយៗទៀត។

សូមអរគុណ!

# មាតិកា


១. សេចក្តីផ្តើម....................................................................................៦

១.១ និយមន័យកសិរុក្ខកម្ម....................................................................៨

១.២ ផលប្រយោជន៍នៃកសិរុក្ខកម្ម..........................................................៨

១.៣ កសិរុក្ខកម្ម និងអាហារូបត្ថម្ភ..........................................................១០

២. ការជ្រើសរើសទីតាំង.......................................................................១១

២.១ ទីកន្លែង.......................................................................................១១

២.២ ប្រភេទដី......................................................................................១១

៣. ការរៀបចំទីតាំង............................................................................១២

៣.១ ការដាំកូនឈើធ្វើជារបង.................................................................១២

៣.២ ការដាំដំណាំចម្រុះនៅក្នុងចម្ការកសិរុក្ខកម្ម........................................១៣

៣.៣ ការដាំដំណាំតាមចន្លោះជួរដើមឈើ.....................................................១៣

៣.៤ ការដាំដំណាំតាមទីជម្រាល...............................................................១៤

៤. ការជ្រើសរើសពូជ...........................................................................១៥

៤.១ ប្រភេទកូនឈើ.............................................................................១៥

៤.២ ប្រភេទបន្លែ.................................................................................១៨

៥. របៀបនៃការដាំដុះ..........................................................................១៩

៥.១ ការដាំដំណាំ.................................................................................១៩

៥.២ ការដាំកូនឈើ..............................................................................២១

៦. ដីកំប៉ុស្តិ៍........................................................................................២២

៦.១ ការធ្វើដីកំប៉ុស្តិ៍...............................................................................២២

៦.២ ពំនូកកំប៉ុស្តិ៍...................................................................................២៣

៧. ការគ្រប់គ្រង និងថែទាំ....................................................................២៤

៧.១ ការថែទាំកូនបណ្តុះ.........................................................................២៤

៧.២ ការលូតលាស់របស់កូនបណ្តុះ.............................................................២៥

៧.៣ ការត្រួតពិនិត្យ..............................................................................២៦

៨. ការប្រមូលផល និងទីផ្សារ................................................................២៧

៩. ការជ្រើសរើស និងទុកដាក់គ្រាប់ពូជ....................................................២៨



landworkersalliance.org.uk


FFI


maierandmaierphotography.com

# ១.សេចក្ដីផ្ដើម

ព្រៃឈើផ្ដល់សារៈសំខាន់ធំធេងដល់មនុស្ស និងសត្វនៅលើផែនដី។ ព្រៃឈើជាប្រភពអាហារប្រភពចំណូលទីជម្រក និងជាតំបន់ទេសចរណ៍ដ៏ទាក់ទាញ។

ដូច្នេះ ការថែរក្សាព្រៃឈើ ការគ្រប់គ្រងទីជម្រាល និងការដាំដុះតាមប្រព័ន្ធកសិរុក្ខកម្មគឺពិតជាមានសារៈប្រយោជន៍ដល់ការចិញ្ចឹមជីវិតរបស់ប្រជាសហគមន៍ ស្ថិរភាព និងសេវាកម្មបរិស្ថាន និងជីវៈចម្រុះ។

សម្រាប់អ្នកដែលទទួលបានឯកសារនេះ គឺជាអ្នកដែលមានដីជាកម្មសិទ្ធិ ហើយសង្ឃឹមថាខ្លឹមសារនៅក្នុងសៀវភៅនេះនឹងជួយដល់ពួកគេជាពត៌មាន ក្នុងការសម្រេចចិត្តអំពីរបៀបគ្រប់គ្រងដីរបស់ពួកគេ។

កសិរុក្ខកម្ម ជួយទ្រទ្រង់ជីវភាពសហគមន៍ ផ្ដល់សេវាកម្មបរិស្ថាន និងធ្វើឲ្យប្រសើរឡើងនូវការអភិរក្សជីវចម្រុះ។



FFI Cambodia



FFI Cambodia

➤ កាប់ព្រៃឈើអាចបង្កឲ្យមានផលប៉ះពាល់ដូចជា៖

- បង្កើនកំដៅក្នុងខ្យល់ ដី និងផ្លាស់ប្តូរលក្ខណៈជីវសាស្ត្រនៃផលិតភាពកសិកម្ម
- បង្កើនការហូរច្រោះដី និងបាត់បង់ជីជាតិក្នុងដី
- កាត់បន្ថយភាពរឹងមាំនៃឬសរបស់ព្រៃឈើ ឬ រុក្ខជាតិ
- បាត់បង់ទីជម្រករបស់រុក្ខជាតិ និងសត្វ
- បាត់បង់ប្រព័ន្ធជីវចម្រុះ
- គ្រោះរាំងស្ងួត និងគ្រោះទឹកជំនន់
- បាត់បង់សោភ័ណ្ឌភាពភូមិសាស្ត្រ
- បាត់បង់របាំងការពារខ្យល់ព្យុះ
- ផ្លាស់ប្តូរលក្ខខណ្ឌទីជម្រាល ដែលនាំឲ្យប៉ះពាល់ដល់ព្រៃឈើ និងសហគមន៍ជាច្រើន
- បង្កឲ្យមានភ្លើងឆេះព្រៃ




➤ តួនាទីទីជម្រាល

- ផ្តល់សេវាកម្មបរិស្ថានប្រកបដោយនិរន្តរភាព
- ផ្តល់បរិមាណទឹកគ្រប់គ្រាន់ និងមានគុណភាពល្អ
- ផ្តល់ធនធានធម្មជាតិយូរអង្វែង
- រក្សាបានស្ថិរភាពជីវភាពរស់នៅ



## ១.១ និយមន័យកសិរុក្ខកម្ម

កសិរុក្ខកម្ម គឺជាការដាំកូនឈើ និងដំណាំនៅលើដីកសិដ្ឋាននៅជុំវិញផ្ទះ ដីដែលកំពុងប្រើប្រាស់ ឬដីចម្ការដែលនៅទំនេរ។ កសិរុក្ខកម្មអាចធ្វើឲ្យកាន់តែប្រសើរឡើងនូវការប្រើប្រាស់ដីដែលទំនេរ ដើម្បីទាញយកផលពីការដាំដុះកូនឈើ និងដំណាំរួមផ្សំផ្សេងៗក្នុងកម្រិតខ្ពស់គួរជាទីគាប់ចិត្ត។










## ១.២ ផលប្រយោជន៍នៃកសិរុក្ខកម្ម

កសិរុក្ខកម្ម អាចផ្តល់នូវផលប្រយោជន៍យ៉ាងច្រើន ដែលអាចលើកកម្ពស់ជីវភាពរបស់ប្រជាសហគមន៍ រួមចំណែកក្នុងការការពារព្រៃឈើ ការផ្តល់សេវាកម្មបរិស្ថាន ការធ្វើឲ្យកើនឡើងនូវជីវចម្រុះ និងភាពល្អប្រសើរនៃបរិស្ថាននៅជុំវិញ។

➤ សារៈប្រយោជន៍នៃកសិរុក្ខកម្មមានដូចជា៖

- ✔ ប្រភពចំណូលសម្រាប់គ្រួសារ
- ✔ ជួយសម្រួលសីតុណ្ហភាព និងទាក់ទាញទឹកភ្លៀង
- ✔ ប្រភពអាហារ (ផ្លែឈើ និងបន្លែ......)
- ✔ ផ្តល់អុកស៊ីសែន និងស្រូបយកឧស្ម័នកាបូនិច
- ✔ ជារបងការពារព្រំដី
- ✔ របាំងការពារខ្យល់
- ✔ អុស និងធ្យូង
- ✔ សាងសង់ផ្ទះ និងគ្រឿងសង្ហារឹម
- ✔ ឱសថព្យាបាលជំងឺ
- ✔ ការពារពីការហូរច្រោះដី
- ✔ ចំណីសត្វ
- ✔ ផ្តល់នូវជីវចម្រុះ
- ✔ ការពារគ្រោះរាំងស្ងួត និងទឹកជំនន់












## ១.៣ កសិរុក្ខកម្ម និងអាហារូបត្ថម្ភ

កសិរុក្ខកម្ម អាចជួយទ្រទ្រង់ផ្នែកសន្តិសុខស្បៀង និងអាហារូបត្ថម្ភដល់សមាជិកគ្រួសារម្នាក់ៗ តាមរយៈការផ្តល់ជាម្ហូបអាហារគ្មានជាតិគីមីពុល ការផ្តល់ប្រាក់ចំណូលបន្ថែមសម្រាប់កសិករ និងការផ្តល់ជាអុសសម្រាប់ចម្អិនអាហារជាដើម។

កសិរុក្ខកម្ម អាចផ្តល់ជាផលិតផលបន្លែ ផ្លែឈើ ស្លឹកឈើ ឬស្លឹករុក្ខជាតិ ដែលមានវីតាមីនខ្ពស់ និងគ្រាប់ធញ្ញជាតិច្រើនយ៉ាងដែលអាចបរិភោគបាន និងធ្វើឲ្យយើងមានសុខភាពល្អ ព្រមទាំងអាចបម្រើដល់សេចក្តីត្រូវការផ្នែកស្បៀងអាហារជាច្រើនទៀតដល់ប្រជាសហគមន៍។



oired.vt.edu



cambodian-fruit-blogspot.com

# ២. ការជ្រើសរើសទីតាំង

## ២.១ ទីកន្លែង

- នៅជិតផ្ទះ
- នៅជិតប្រភពទឹក
- នៅកន្លែងមិនលិច ឬមានទឹកជោគជាំ
- នៅលើដីកំពុងប្រើប្រាស់ ឬដីដែលទំនេរ

## ២.២ ប្រភេទដី

- ដីល្បាប់សមស្របបំផុតសម្រាប់ការដាំដុះ
- ដីពាក់កណ្តាលជម្រាល
- ដីដែលមានកម្ទេចកម្ទីរុក្ខជាតិពុកផុយ
- ដីខ្សាច់ ដីឥដ្ឋ និងដីហាប់មិនសមស្របសម្រាប់ដាំទេ
- ដីខ្សោះជីជាតិមិនអាចដាំកូនឈើបានទេ






# ៣. ការរៀបចំទីតាំង

## ៣.១ ការដាំកូនឈើធ្វើជារបង

- ដើមឈើខ្លះអាចដាំតាមជាយចំការ ឬ តាមរបងផ្ទះ
  ឧទាហរណ៍ (កន្ទំថេត ស្ពុំ អង្គាសដី ម្រុំ......)
- ដើមខ្លះអាចកំណត់ព្រំដី និងអាចការពារខ្យល់បក់
- ដើមឈើដែលលូតលាស់លឿន
  ឧទាហរណ៍ (ដើមគរ ល្ហុង ចេក.........)
- ដើមឈើដែលអាចផ្តល់ម្លប់
  ឧទាហរណ៍ (ដើមស្វាយ ខ្នុរ ប៉ូរ ធូរេន.........)






## ៣.២ ការដាំដំណាំចម្រុះនៅក្នុងចម្ការកសិរុក្ខកម្ម

- គឺជាការដាំដំណាំកូនឈើ និងដំណាំផ្សេងៗគ្នាចាប់ពីពីរប្រភេទឡើងទៅនៅលើផ្ទៃដីតែមួយ
- ការដាំចម្រុះគ្នាបែបនេះអាចផ្តល់នូវទិន្នផលខ្ពស់ជាងការដាំដំណាំតែមួយមុខ


intranet.fintrac.com


researchgate.net

## ៣.៣ ការដាំដំណាំតាមចន្លោះជួរដើមឈើ

- អាចផ្តល់ការលូតលាស់ស្របពេលជាមួយគ្នា
- ត្រូវលះមែកដើមឈើណាដែលបាំងពន្លឺថ្ងៃដល់ដំណាំ
- អាចជួយធ្វើឲ្យដីមានជីជាតិក្នុងរយៈពេលយូរ
- ការដាំដំណាំតាមចន្លោះជួរគួរធ្វើឡើងចំពោះដីដែលរាបស្មើ


intranet.fintrac.com

# ៣.៤ ការដាំដំណាំតាមទីជម្រាល

- ➤ កាត់មែកឈើដើម្បីរក្សាជារបងរស់មានកម្ពស់ពី ១ - ១,៥ម៉ែត្រ
- ➤ ដើមឈើដាំជារបង គួរដាំតាមបណ្ដោយដីជម្រាលដូចជាខ្សែកោង



intranet.fintrac.com

## ប្លង់សម្រាប់ជ្រើសរើសទីតាំងកសិរុក្ខកម្ម




The Leanring Institute

# ៤. ការជ្រើសរើសពូជ

## ៤.១ ប្រភេទកូនឈើ

ប្រភេទកូនឈើដែលល្អបំផុតដើម្បីដាំដុះរួមគ្នាជាមួយដំណាំ៖

- ✔ មានឫសវែងចាក់ទៅដីជ្រៅដើម្បីស្រូបយកទឹក
- ✔ អាចឲ្យពន្លឺឆ្លងកាត់ស្លឹកដើម្បីធានាដល់ការលូតលាស់
- ✔ នៅតែលូតលាស់ទោះជាកាត់មែកជាប្រចាំក៏ដោយ
- ✔ ស្លឹករបស់វាអាចធ្វើជាចំណីមនុស្ស សត្វ ជាបន្លែ ផ្លែឈើ
- ✔ អាចប្រើប្រាស់ជាអនុផលព្រៃឈើលក្ខណៈគ្រួសារ

ជាទូទៅដើមឈើអាចរក្សាលំនឹងអាសូតដោយទាញយកអាសូតពីខ្យល់អាកាស និងបញ្ជូនបន្តទៅឲ្យរុក្ខជាតិដទៃទៀតដែលដុះលើដី។ ចំពោះស្លឹកឈើទុំដែលជ្រុះនៅលើដី បានប្រែក្លាយទៅជាសារធាតុចិញ្ចឹមដល់រុក្ខជាតិនានាដែលដុះនៅជុំវិញនោះ ឬសម្រាប់ធ្វើជាជីកំប៉ុស្តិ៍ដើម្បីប្រើប្រាស់លើដំណាំគ្រប់ប្រភេទឲ្យលូតលាស់បានល្អ។






ដើមឈើរក្សាលំនឹងអាសូតមានស្លឹកច្រើនផ្គុំគ្នាជារាងស្លាបសត្វ។ ស្លឹកអាចតូច ឬធំ ប៉ុន្តែជាទូទៅវាផ្គុំគ្នាជារាងមួយស្រដៀងគ្នា។



intranet.fintrac.com

ដើមឈើរក្សាលំនឹងអាសូតទាំងអស់មានផ្លែ ដែលមានគ្រាប់នៅក្នុងស្រោមដូចជា ផ្លែអំពិល និងផ្លែកន្ធំថេត សណ្តែកដី សណ្តែកបាយ ឬសណ្តែកក្រហម ដែលមានសារៈសំខាន់សម្រាប់ការដាំដំណាំឆ្លាស់។



intranet.fintrac.com

ដើមឈើរក្សាលំនឹងអាសូតមានច្រើនប្រភេទណាស់ ចំណែកនៅក្នុងប្រទេសកម្ពុជាដើមឈើទាំងនោះមានដូចជា៖

| ល.រ | ឈ្មោះក្នុងស្រុក | ឈ្មោះវិទ្យាសាស្ត្រ |
|---|---|---|
| ១ | ដើមស្នំ | Acacia pennata |
| ២ | ដើមច្រេស | Albiza lebbeck |
| ៣ | ដើមក្រញូង | Dalbergia cochinchinensis |
| ៤ | ដើមសម្លាប់កណ្ដុរ | Gliricidia sepium |
| ៥ | ដើមអង្គាដី | Sesbania grandiflora |
| ៦ | ដើមធ្នង់ | Pterocarpus indicus |
| ៧ | ដើមអំពិល | Tamarindus indica |
| ៨ | ដើមកន្ធំថេត | Leucaena: leucocephala and diversifolia |
| ៩ | ដើមព្រះខ្លប | Mimosa pudica |
| ១០ | ដើមអង្គាញ់ | Senna siamea (Cassia) |







តារាងខាងក្រោមនេះជាប្រភេទដើមឈើដែលបានសាកល្បងដាំនៅឃុំអូរសោម ស្រុកវាលវែង ខេត្តពោធិ៍សាត់ កន្លងមកដោយក្រុមការងារអង្គការសត្វព្រៃ និងរុក្ខជាតិអន្តរជាតិ បានសហការជាមួយនឹងវិទ្យាស្ថានសិក្សាស្រាវជ្រាវ និងបណ្តុះបណ្តាល។

| ល.រ | ឈ្មោះក្នុងស្រុក | ឈ្មោះជាភាសាអង់គ្លេស/ ឈ្មោះតំបន់ | ឈ្មោះវិទ្យាសាស្ត្រ |
|---|---|---|---|
| ១ | បេង | Beng | Afzelia xylocarpa (Kurz) Craib. |
| ២ | ក្រូច | Lemon* | Citrus |
| ៣ | ខ្នុរ | Jack fruit | Artocarpus heterophyllus |
| ៤ | ក្រញូង | Kranhoung | Dalbergia cochinchinensis Pierre |
| ៥ | ត្បែង | Tbeng | Dipterocarpus obtusifolius |
| ៦ | ស្ដៅ | Neem | Azadirachta indica Ant. Juss. |
| ៧ | ឆៃយ៉ា | Chaya | Cnidoscolus aconitifolius |
| ៨ | ងុប | Katuk | Sauropus androgynus |
| ៩ | ទៀបបារាំង | Sour sop | Annona muricata |
| ១០ | ចាន់ក្រឹស្នា | Agarwood | Aquilaria crassna |
| ១១ | ដើមសម្លាប់កណ្ដុរ | Salab kandor | Gliricidia sepium (cuttings) |

# ៤.២ ប្រភេទបន្លែ

នៅកម្ពុជាយើង មានដំណាំច្រើនណាស់ ដែលកសិករអាចដាំបាន។ ជាទូទៅគេជ្រើសរើសដំណាំដោយមានលក្ខណៈពិសេសមួយចំនួន ដូចជាភាពសមស្របទៅតាមរដូវកាល ដីជាតិដី ទីតាំង តម្រូវការគ្រួសារ ឬសម្រាប់លក់ក្នុងមូលដ្ឋាន ងាយស្រួលក្នុងការដាំដុះនិងទុកដាក់ពូជ។ ខាងក្រោមនេះជាដំណាំបន្លែមួយចំនួនដែលកសិករគួរជ្រើសរើសដាំ៖

| | | |
|---|---|---|
| - ស្លឹកបាស | - ត្រប់ | - ក្រូចឆ្មារ |
| - ផ្ទី | - ម្ទេស | - ចេក |
| - ត្រកួន | - ពពាយ | - ល្ហុង |
| - ជ្រលង់ | - សណ្តែកកួរ | - ឃ្លោក |
| - ស្លឹកគ្រៃ | - ម្រះ | - ដំឡូងជ្វា |
| - ជីគ្រប់ប្រភេទ | - ននោង | - ដំឡូងមី |
| - ខ្ទឹម | - ខ្ញី | - ត្រឡាច |
| - ត្រាវ | - រំដេង | - ល្ពៅ |
| - ដំឡូងដៃខ្លា | - ល្មៀត | - ត្រសក់ |








# ៥. របៀបនៃការដាំដុះ

## ៥.១ ការដាំដំណាំ

- ➤ ចម្ងាយពីរងមួយទៅរងមួយទៀត ១,៥ម៉ែត្រ
- ➤ វាស់គិតចាប់ពីរចំណុចកណ្តាលពីរងមួយទៅចំណុចកណ្តាលរងមួយទៀត (រូបទី១)
- ➤ ចន្លោះគុម្ពមានការប្រែប្រួលខុសៗគ្នាអាស្រ័យទៅតាមមុខដំណាំដែលយកមកដាំ




រូបទី១

intranet.fintrac.com

### ក. សណ្ឋានរងទី១

- ➤ សម្រាប់ដំណាំវារឡើងទ្រើងដូចជា (ត្រសក់ ម្រះ និង សណ្តែកកួរ)
- ➤ រងដំណាំគួរមានសណ្ឋាន ជាចតុកោណព្នាយ មានផ្ទៃរាបស្មើ
- ➤ ទទឹងខ្នងរងមិនលើសពី ២០សង់ទីម៉ែត្រ
- ➤ ទទឹងបាតរងគួរមានទំហំ ១ម៉ែត្រ និងកម្ពស់ ៣០សង់ទីម៉ែត្រ

### ខ. សណ្ឋានរងទី២

- ➤ ដំណាំដែលដាំជាពីរជួរក្នុងមួយរង ដូចជា ពោត ស្ពៃក្តោប និងម្ទេស
- ➤ ទទឹងខ្នងរងគួរមានប្រវែង ៦០ ទៅ ៧០សង់ទីម៉ែត្រ
- ➤ កម្ពស់រង ២៥សង់ទីម៉ែត្រ និងទទឹងបាតរងប្រវែង ១ម៉ែត្រ




ក. សណ្ឋានរងទី១




ខ. សណ្ឋានរងទី២

intranet.fintrac.com

## គ. សណ្ឋានរងទី៣

- ➤ ដំណាំដែលដាំបីជួរក្នុងមួយរង ដូចជា ស្ពៃតឿ និងស្ពៃក្រញាញ់
- ➤ ទទឹងខ្នងរងគួរមានប្រវែង ៧០ ទៅ ៨០សង់ទីម៉ែត្រ
- ➤ កម្ពស់រង ២០សង់ទីម៉ែត្រ និងទទឹងបាតរងប្រវែង ១ម៉ែត្រ




intranet.fintrac.com

គ. សណ្ឋានរងទី៣

## ឃ. សណ្ឋានរងទី៤

- ➤ រងដែលដាំបួនជួរក្នុងមួយរង ដូចជា ត្រកួន សាលាដ និងផ្ទី
- ➤ ទទឹងខ្នងរងគួរមានប្រវែង ៨០ ទៅ ៩០សង់ទីម៉ែត្រ
- ➤ កម្ពស់រង ១៥សង់ទីម៉ែត្រ (អាចខ្ពស់ជាងនេះក៏បាន)




intranet.fintrac.com

ឃ. សណ្ឋានរងទី៤

## ង. គំរូនៃការដាំកូនដំណាំ

- ➤ នៅពេលដាំដំណាំច្រើនជួរក្នុងមួយរង ចូរដាំជារាង ត្រីកោណ ឬខ្វែងគ្នា



ង. គំរូនៃការដាំកូនដំណាំ

intranet.fintrac.com

## ៥.២ ការដាំកូនឈើ

- ដោតកំណាត់ឫស្សី ឬបង្គោល
- ជីករណ្តៅ និងហាលថ្ងៃមួយសប្តាហ៍សិនមុននឹងដាំកូនឈើ
- រណ្តៅមានរាងជាការ៉េទំហំ ៣០ x ៣០សង់ទីម៉ែត្រ និងមានជម្រៅ ៣០សង់ទីម៉ែត្រ
- ពេលដាំត្រូវកាយដីស្រទាប់លើលុបរណ្តៅមុន



FFI Cambodia

- ហែកថង់ប្លាស្ទិកចេញពីកូនឈើដោយថែរក្សាដីដែលស្រោបឫសកូនឈើកុំឲ្យបែក
- ដាក់កូនឈើទៅក្នុងរណ្តៅ ហើយលប់ដីត្រឹមគល់កូនឈើ
- ត្រូវប្រុងប្រយ័ត្នកុំឲ្យបែកដី បាក់ដើម និងខូចឫស
- បង្ហាប់ដីនៅជុំវិញកូនឈើ
- ស្រោចទឹក



dl.dropboxusercontent.com

- ជាទូទៅពេលវេលានៃការដាំកូនឈើ គេនិយមដាំនៅដើមរដូវភ្លៀង (ដើមខែឧសភា - ដើមខែមិថុនា)
- ដាំនៅពេលមានមេឃស្រទុំ ឬ នៅពេលល្ងាច



imgarcade.com

# ៦. ដីកំប៉ុស្តិ៍

ដីកំប៉ុស្តិ៍ ជាដីធម្មជាតិដែលផ្សំឡើងដោយវត្ថុធាតុផ្សេងៗ ដូចជា លាមកសត្វ ស្លឹកទន្ទ្រានខែត្រ ស្លឹកឈើងាប់ ស្លឹកឈើជ្រុះ ធាងចេក និង ដើមចេក ចំបើង ស្មៅងាប់ កំប្លោក ចក ផេះ កំបោរ និងកាកសំណល់ ផ្សេងៗពីផ្ទះបាយ។ ទន្ទឹមនឹងនេះ គេក៏អាចប្រើកាកសំណល់បន្លែ ផ្លែឈើ ដែលសល់ពីផ្ទះបាយ និងតាមទីផ្សារ។ ដីកំប៉ុស្តិ៍អាចផ្តល់សារធាតុចិញ្ចឹម ច្រើនមុខដល់រុក្ខជាតិក្នុងរយៈពេលយូរមួយ។ ក្រៅពីនេះវាក៏ជួយឲ្យដីយើង បានផុសល្អដែរ។



kairophotos.photoshelter.com

## ៦.១ ការធ្វើដីកំប៉ុស្តិ៍

- ➤ សារធាតុពណ៌បៃតង៖ ស្លឹកឈើស្រស់ កាកសំណល់ផ្ទះបាយ បន្លែរលួយ លាមកសត្វ កាកកាហ្វេ
- ➤ សារធាតុពណ៌ត្នោត៖ ចំបើង មែកឈើ អាចម៍រណា ក្រដាស អង្កាម សំបកគ្រាប់ធញ្ញជាតិ (ពោត សណ្តែកដី សណ្តែកបាយ.........)



មែកឈើ



កាកសំណល់ផ្ទះបាយ



សំបកសណ្តែកដី



អាចម៍គោ



កាកកាហ្វេ



ចំបើង



អាចម៍រណា



អង្កាម

google.com

# ៦.២ ពំនូកកំប៉ុស្តិ៍

- ចាប់ផ្តើមដោយការដាក់សារធាតុពណ៌ត្នោតកម្រាស់ ១៥,២០ ស.ម នៅក្នុងទីកន្លែងដែលមានទំហំប្រហែលមួយម៉ែត្រការ៉េ
- បន្ថែមសារធាតុពណ៌បៃតងកម្រាស់ ១០,១៥ ស.ម មួយស្រទាប់ទៀតនៅពីលើស្រទាប់សារធាតុពណ៌ត្នោត
- ពង្រាយដីមមោកស្តើរៗពីលើស្រទាប់សារធាតុបៃតង
- ស្រទាប់ទាំងអស់នេះត្រូវតែសើម តែមិនជោគជាំពេក
- បន្ថែមទឹកតាមការចាំបាច់ ជាពិសេសនៅរដូវប្រាំង
- ពំនូកកំប៉ុស្តិ៍មានកម្រាស់ប្រមាណ ១ - ១,៥ ម៉ែត្រ
- តង់/បន្ទះផ្លាស្ទិកគួរយកមកគ្របគំនរដីកំប៉ុស្តិ៍
- គួរត្រួតពិនិត្យកម្តៅដើម្បីឲ្យប្រាកដថាដំណើរការបំបែកធាតុត្រឹមត្រូវ
- បន្ទាប់ពី១ទៅ៣សប្តាហ៍ ត្រឡប់ពំនូកកំប៉ុស្តិ៍ ឬ ច្របល់ត្រឡប់ចុះឡើង
- ពេលដែលពំនូកត្រជាក់ ត្រូវត្រឡប់វាចុះឡើងម្តងទៀត
- ជាមធ្យមការផលិតដីកំប៉ុស្តិ៍មានរយៈពេល ៤ - ៦សប្តាហ៍


thegreenshots.wordpress.com



intranet.fintrac.com

# ៧. ការគ្រប់គ្រង និងថែទាំ

## ៧.១ ការថែទាំកូនបណ្តុះ

- ត្រូវរក្សាកូនបណ្តុះតែមួយដើមប៉ុណ្ណោះក្នុងកន្ទោងនីមួយៗ
- គម្លាតដែលល្អបំផុតសម្រាប់កូនបណ្តុះ គឺប្រហែល ៥ស.ម ពីគែមមកកូនបណ្តុះ
- ដកយកកូនបណ្តុះចូលក្នុងថង់ដែលមានដី
- ជ្រោយដីឲ្យធូរដោយប្រើកាំបិត លើកយកកូនបណ្តុះឡើងធ្វើយ៉ាងណាឲ្យមានដោយដីខ្លះមកជាមួយឫស
- បន្ទាប់មកដាក់វាដាំសារថ្មីដោយប្រុងប្រយ័ត្ននៅក្នុងកន្ទោងទំនេរ
- ចាក់ដីឲ្យបង្កើតបានជារន្ធ
- ដាក់កូនបណ្តុះចូលទៅក្នុងរន្ធនោះ
- រន្ធត្រូវឲ្យធំទូលាយ និងជ្រៅសម្រាប់ឫស
- បន្ទាប់ពីដាក់កូនបណ្តុះចូលទៅក្នុងរន្ធ ត្រូវយកដីកប់នៅជុំវិញកូនបណ្តុះនោះ
- មិនត្រូវដាក់កូនបណ្តុះនោះឲ្យជ្រៅពេកទេ
- ថែទាំកូនបណ្តុះឲ្យបានល្អដោយដកស្មៅ និងរុក្ខជាតិចង្រៃតូចៗ



dl.dropboxusercontent.com




dl.dropboxusercontent.com

## ៧.២ ការលូតលាស់របស់កូនបណ្ដុះ

- រៀបចំដីឲ្យមានលក្ខណៈខូងបន្តិចនៅជុំវិញកូនឈើ ដើម្បីចាប់ទឹក និងដករុក្ខជាតិចង្រៃចេញ
- ពូនគល់កូនឈើជាមួយចំបើង សម្រាម ឬរុក្ខជាតិដើម្បីជួយបង្កើនសំណើមក្នុងដី (រូបភាពទី១)
- ប្រសិនបើកូនឈើត្រូវគេដាំនៅទីជម្រាល គឺត្រូវពូនដីឲ្យមានរាងជាអក្សរ V ដើម្បីចាប់យកទឹកនិងរក្សាទឹកភ្លៀងទុក (រូបភាពទី២)
- ក្នុងកំឡុងពេលរដូវប្រាំងខ្សត់ខ្សោយទឹកហើយកូនបណ្ដុះត្រូវបានគេដាំនៅក្បែរផ្ទះ ឬនៅក្បែរប្រភពទឹក គឺត្រូវចាក់បំពេញទឹកក្នុងដប ហើយត្រូវផ្កាប់ដបនោះដោយសង្កត់ចូលក្នុងដីយ៉ាងរហ័សនៅក្បែរឫសរបស់កូនបណ្ដុះនោះ។ ទឹកក្នុងដបនោះនឹងជ្រាបយ៉ាងយឺតៗចូលទៅក្នុងដី (រូបភាពទី៣)
- ការពារកូនឈើពីសត្វពាហនៈផ្សេងៗដោយប្រើមែកឈើ ឬបន្លា ឬសង់របងព័ទ្ធជុំវិញកូនឈើនោះ (រូបភាពទី៤)


រូបភាពទី១
dl.dropboxusercontent.com


រូបភាពទី២
dl.dropboxusercontent.com


cedac.org
រូបភាពទី៣
dl.dropboxusercontent.com


រូបភាពទី៤

# ៧.៣ ការត្រួតពិនិត្យ

ការត្រួតពិនិត្យនឹងជួយរកឲ្យឃើញនូវមូលហេតុ ដើម្បីស្វែងរកដំណោះស្រាយសមស្រប សម្រាប់កាត់បន្ថយផលប៉ះពាល់អវិជ្ជមានចំពោះកូនឈើដែលបានដាំ។ មូលហេតុនៃការស្លាប់កូនឈើ គឺភាគច្រើនបណ្តាលមកពីៈ

- ភាពរាំងស្ងួត និងទឹកជំនន់
- ការឃាយីដោយការលែងសត្វពាហនៈ
- សត្វល្អិត និងជំងឺផ្សេងៗ (រូបភាពទី ៥)

រូបភាពទី៥



intranet.fintrac.com

# ៨. ការប្រមូលផល និងទីផ្សារ

រដូវប្រមូលផលផ្លែឈើ និងបន្លែ គឺជាពេលវេលាមួយដ៏សំខាន់បំផុតដែលប្រជាសហគមន៍មានសេចក្ដីសប្បាយរីករាយចំពោះផលបន្លែផ្លែឈើ ដែលបានដាំដុះកន្លងមក។ ការប្រមូលផល និងលក់ទៅកាន់ទីផ្សារនឹងអាចរួមចំណែកលើកស្ទួយជីវភាពរស់នៅរបស់ប្រជាសហគមន៍បានមួយកម្រិត។ ក្នុងពេលប្រមូលផល យើងគួរចងចាំថា៖

- គួរតែប្រមូលផលផ្លែឈើ និងបន្លែនៅពេលព្រឹកព្រហាមស្រាងៗពេលដែលអាកាសធាតុត្រជាក់
- មិនត្រូវប្រមូលផលផ្លែឈើ និងបន្លែនៅពេលថ្ងៃក្ដៅនោះទេ ព្រោះវាអាចធ្វើឲ្យផ្លែឈើ និងបន្លែទាំងនោះស្រពោន
- បន្ទាប់ពីប្រមូលផលរួច មិនត្រូវដាក់ផ្លែឈើ និងបន្លែឲ្យត្រូវកម្ដៅថ្ងៃទេ
- មិនត្រូវប្រមូលផលផ្លែឈើ និងបន្លែពេលកំពុងភ្លៀងទេ ព្រោះវាអាចងាយស្អុយរលួយ
- បេះស្លឹកចេញ និងជៀសវាងកុំឲ្យផ្លែឈើ និងបន្លែខូចជាំ ឬមានសត្វល្អិត ឬដង្កូវស៊ី
- ត្រូវរៀបចំផ្លែឈើ និងបន្លែតាមប្រភេទ និងពណ៌ជាក្រុមៗ
- នៅពេលវេចខ្ចប់ ត្រូវប្រាដកថាផ្លែឈើ និងបន្លែស្ថិតក្នុងសភាពស្ងួត ដោយមិនត្រូវវេចខ្ចប់ខ្លាំងពេកទេ ព្រោះអាចបណ្ដាលឲ្យខូចជាំ
- ប្រសិនត្រូវស្ដុកទុកមុននឹងដឹកជញ្ជូនទៅទីផ្សារ ត្រូវប្រាកដថាផ្លែឈើ និងបន្លែទាំងនោះស្ថិតក្នុងសភាពត្រជាក់ និងស្ងួត


theguardian.com


phnompenhpost.com

# ៩. ការជ្រើសរើស និងទុកដាក់គ្រាប់ពូជ

ដើម្បីជ្រើសរើសគ្រាប់ពូជឲ្យបានល្អ ជាដំបូងត្រូវកំណត់ដើមឈើសម្រាប់ធ្វើពូជ ដូចមានសណ្ឋានខាងក្រោម៖

- ដើមល្អគ្មានជំងឺ
- ដើមឈរខ្ពស់មានមែកច្រើន ហើយស្លឹកលូតលាស់ល្អ
- ជាដើមមេមានទ្រង់ទ្រាយផ្តល់ផ្លែល្អ

ចំណែកការជ្រើសរើសគ្រាប់វិញក៏ត្រូវមានលក្ខណៈល្អ ដើម្បីធានាដល់ការដាំដុះឡើងវិញ ដោយលក្ខខណ្ឌជ្រើសរើសមានលក្ខណៈសម្គាល់ដូចតទៅ៖

- គ្រាប់ថ្លោសល្អ
- គ្រាប់មានទម្ងន់ធ្ងន់
- គ្រាប់មានពណ៌សម្បុរល្អ (ពណ៌ទុំរបស់វា)
- ការប្រមូលគ្រាប់ពូជ (នៅពេលចាប់ផ្តើមទុំ)អាស្រ័យទៅតាមប្រភេទឈើនីមួយៗ

ជាទូទៅគ្រាប់ត្រូវប្រមូលភ្លាមៗនៅពេលវាទុំ ហើយរក្សាទុកនៅទីកន្លែងស្ងួត ដើម្បីស្តុកទុកក្នុងរយៈពេល ១ ឬ ២ឆ្នាំ។


shroomery.org


gv-association.org

# ឯកសារយោង


១. ព្រឹត្តិបត្របច្ចេកទេស របស់គម្រោង HARVEST

លេខ ៣១ ស្តីពី ដំបូន្មានអំពីចន្លោះគុម្ពដំណាំ ចំពោះដំណាំសាកវប្បកម្ម
លេខ ៦២ ស្តីពី ជីកំប៉ុស្ត៍
លេខ ៦៤ ស្តីពី ផលប៉ះពាល់នៃបរិស្ថានវិទ្យាពីការកាប់បំផ្លាញព្រៃឈើ
លេខ ៦៩ ស្តីពី តួនាទីរបស់ទីជម្រាល
លេខ ៧០ ស្តីពី ទីជម្រាលដែលងាយរងគ្រោះ
លេខ ៧៥ ស្តីពី ការថែទាំ និងត្រួតពិនិត្យកូនឈើក្រោយពេលដាំ
លេខ ៩៤ ស្តីពី ដំបូន្មានបច្ចេកទេសពេលប្រមូលផល និងក្រោយពេលប្រមូលផលម្ទេស
លេខ ៩៥ ស្តីពី កសិបរិស្ថានវិទ្យា៖ មូលដ្ឋានគ្រឹះនៃកសិរុក្ខកម្ម និងចម្ការឈើដាំ
លេខ ៩៦ ស្តីពី ការដាំដំណាំចម្រុះនៅក្នុងចម្ការកសិរុក្ខកម្ម
លេខ ៩៧ ស្តីពី ដើមឈើត្រូវការអាសូត

២. ខូវ បាន រតនៈ (២០០៧) ស្តីពី កសិរុក្ខកម្ម

៣. រដ្ឋបាលព្រៃឈើ និងគម្រោងថ្នាក់គ្រាប់ពូជឈើកម្ពុជា (២០០៥) ស្តីពីគោលការណ៍ណែនាំសម្រាប់កំណត់ទីតាំងនិងការអនុវត្តន៍ការងារដាំដើមឈើ

៤. សម វិទូ និង ស៊ឹម សាមឿន (២០០៩) ស្តីពីការបណ្តុះនិងការដាំកូនឈើពហុប្រយោជន៍។ បោះពុម្ពដោយមជ្ឈមណ្ឌលសិក្សានិងអភិវឌ្ឍន៍កសិកម្មកម្ពុជា។

៥. យ៉ង សាំងកុមារ និង ពាន សុខា២០១២ ស្តីពីសៀវភៅសួនដំណាំជាលក្ខណៈគ្រួសារ។ បោះពុម្ពដោយ មជ្ឈមណ្ឌលសិក្សា និងអភិវឌ្ឍន៍កសិកម្មកម្ពុជា។










**វិទ្យាស្ថានសិក្សាស្រាវជ្រាវ និងបណ្តុះបណ្តាល**

ផ្លូវលេខ១១៣ ផ្ទះលេខ៤៥ សង្កាត់បឹងកេងកង៣ ខណ្ឌចំការមន
ភ្នំពេញ កម្ពុជា ប្រអប់សំបុត្រលេខ ២៥០៩
ទូរស័ព្ទ ៨៥៥ (0) ២៣ ៩៩៤ ៩៣៥
ទូរសារ ៨៥៥ (0) ២៣ ២២៤ ១៧១
អ៊ីម៉ែល៖ info@learninginstitute.org
គេហទំព័រ៖ www.learninginstitute.org